លេខ / No: D97/13

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
~~ORIGINAL DOCUMENT/DOC~~UMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / DEC / 2009
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA: Thy

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

លេខសំណុំរឿង: ០០២/១៩-០៩-២០០៧-អ.វ.ត.ក..-ក.ស.ច.ស.

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 09 / DEC / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA: Thy

កាលបរិច្ឆេទ៖ ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០០៩

ភាសាដើម៖ ខ្មែរ /បារាំង

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

## ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម

<u>សហព្រះរាជអាជ្ញា</u>

អ្នកស្រី ជា លាង
លោក William SMITH

<u>ជនត្រូវចោទ</u>

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន
កាំង ហ្គេកអ៊ាវ *ហៅ* ឌុច

<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>

នី ច័ន្ទឌី
គង់ ពិសី
យុង ផានិត
ម៉ុច សុវណ្ណារី
ជេត វណ្ណលី
ឡោ ឈុនធី
ហុង គីមសួន
គីម ម៉េងឃី
ស៊ីន សុវន
ពេជ អង្គ
Silke STUDZINSKY
Phillipe CANONNE
Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud

<u>មេធាវីការពារក្តី</u>

សុន អរុណ Michiel PESTMAN
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅស៊ាង Diana ELLIS
ស សុវាន Jacques VERGES
ការ សាវុត្ថ François ROUX
Marie-Paule CANIZARES

**យើង យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញវិធាន ៥៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ("វិធានផ្ទៃក្នុង")

បានឃើញការបន្តការស៊ើបសួរលើឈ្មោះ **អៀង សារី និង ជនដទៃ** ដែលត្រូវបានដាក់ឲ្យឋិតក្រោមការពិនិត្យលើ**បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ** និង**ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.

បានឃើញសំណើសុំប្រឆាំងនឹងការអនុវត្ត នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា *សហឧក្រិដ្ឋកម្មរួម* ដោយមេធាវីការពារក្តី អៀង សារី (D97) ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨ ("សំណើសុំ")

បានឃើញសំណើ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០០៨ សុំឲ្យមានសវនាការជាសាធារណៈផ្ទាល់មាត់ ឬក៏ជាជំនួសវិញដោយសំណើសុំបន្ថែមពេលវេលាដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព) ទៅនឹងសំណើសុំរបស់មេធាវីការពារក្តី អៀង សារី (D97/1)

បានឃើញការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើសុំរបស់ អៀង សារី អំពីសហឧក្រិដ្ឋកម្មរួម (D97/2) ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៨ ("ចម្លើយតប")

បានឃើញដីការបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៨ ស្នើឱ្យភាគីនានាដាក់ការកត់សំគាល់បន្ថែម លើបញ្ហានេះ ឱ្យបានមុនថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៨ និងឆ្លើយតបទៅនឹងសំណើសុំ D97/3 និងសុំឱ្យមានសវនាការជាសាធារណៈផ្ទាល់មាត់ ឬពេលវេលាបន្ថែម (D97/3)

បានឃើញសំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០០៨ សុំបន្ថែមចំនួនទំព័រកំណត់សម្រាប់ការកត់សំគាល់របស់ខ្លួនលើសហឧក្រិដ្ឋកម្មរួម (Joint Criminal Enterprise: JCE) ស្របតាមដីការបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៨ (D97/4)

បានឃើញសំណើសុំបន្ថែមចំនួនទំព័រកំណត់ សម្រាប់ដាក់ការកត់សំគាល់បន្ថែម ស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ដោយមេធាវីការពារក្តី អៀង សារី (D97/5) ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០៨

បានឃើញដីការបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០០៨ យល់ព្រមចំពោះសំណើរបស់មេធាវីការពារក្តី អៀង សារី និងរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រកំណត់ (D97/6)

បានឃើញការកត់សំគាល់បន្ថែមរបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០៨ (D97/7)

បានឃើញសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០០៨ (D97/3/1)

បានឃើញសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៨ (D97/3/2)

បានឃើញសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៨ (D97/3/3)

បានឃើញសេចក្តីសន្និដ្ឋានរបស់សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៨ (D97/3/4)

បានឃើញលិខិតរបស់មេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៨ (D97/3/5)

បានឃើញការកត់សំគាល់បន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៨ (D97/8)

បានឃើញសំណើរបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ សុំឲ្យដាក់ទណ្ឌកម្មចំពោះសហព្រះរាជអាជ្ញា ដែលនាំឲ្យអង្គជំនុំជម្រះយល់ខុសទាក់ទិននឹងសហឧក្រិដ្ឋកម្មរួម (D97/9)

បានឃើញលិខិតរួមរបស់មេធាវីការពារក្តី ទាក់ទិននឹងសេចក្តីសម្រេចលើការអនុវត្តទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ពីមេធាវីការពារក្តី នួន ជា, អៀង សារី និង ខៀវ សំផន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០០៩ (D97/10) និងចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៩ (D97/11)

បានឃើញសេចក្តីសន្និដ្ឋានលើបញ្ហានៃការដាក់ទណ្ឌកម្ម ដោយមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០០៩ (D97/9/1)

បានឃើញចម្លើយតបលើបញ្ហានៃការដាក់ទណ្ឌកម្ម ដោយសហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០៩ (D97/9/2)

បានឃើញសេចក្តីសន្និដ្ឋានលើបញ្ហានៃការដាក់ទណ្ឌកម្ម ដោយមេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៩ (D97/9/3)

បានឃើញចម្លើយតបរបស់មេធាវីការពារក្តី អៀង សារី ចំពោះសហព្រះរាជអាជ្ញា លើបញ្ហានៃការដាក់ទណ្ឌកម្ម ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៩ (D97/9/4)

បានឃើញសេចក្តីសន្និដ្ឋានបន្ថែមរបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៩ (D97/12) តបនឹងការកត់សំគាល់បន្ថែមទាក់ទិននឹងការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ដែលបានដាក់នៅ ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០៨ ៖ កម្រិតត្រឹមតែសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិដែលអាចអនុវត្តបាន ដូចបានអះអាង/បានបំភ្លេច ដោយ ក.ស.ព

បានឃើញចម្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លើបញ្ហានៃការដាក់ទណ្ឌកម្ម ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០០៩ (D97/9/5)

បានឃើញចម្លើយតបរបស់មេធាវីការពារក្តី អៀង សារី ចំពោះដើមបណ្តឹងរដ្ឋប្បវេណី លើបញ្ហានៃការដាក់ទណ្ឌកម្ម ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៩ (D97/9/6)

បានឃើញដីការបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំរបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ សុំឱ្យដាក់ទណ្ឌកម្មចំពោះសហព្រះរាជអាជ្ញា (D97/9/7)

## I) ការរំលឹកឡើងវិញអំពីនីតិវិធី និង សេចក្ដីសំអាងរបស់ភាគី

១. នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨ មេធាវីការពារក្ដី អៀង សារី បានស្នើសុំ ក.ស.ច.ស ឱ្យសម្រេចថា ទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ("JCE") គឺមិនមែនជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ទេ។ មេធាវីអះអាងថា អនុវត្តន៍ JCE នៅចំពោះមុខ អ.វ.ត.ក គឺជាការរំលោភលើគោលការណ៍ *nullum crimen sine lege* អាស្រ័យដោយទំរង់នៃការទទួលខុសត្រូវនេះមិនត្រូវបានទទួលស្គាល់ជាទំនៀមទម្លាប់នៃច្បាប់អន្តរជាតិទេ ចន្លោះពីឆ្នាំ ១៩៧៥-១៩៧៩ ហើយក៏មិនត្រូវបានទទួលស្គាល់ដែរនាពេលបច្ចុប្បន្ននេះ[1]។ លើសពីនេះទៀត មេធាវីការពារក្ដីបានអះអាងនៅក្នុងសំណើរបស់ខ្លួនថា JCE មិនមានចែងនៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឬក៏នៅក្នុងច្បាប់កម្ពុជាឬត្រូវបានទទួលស្គាល់ដោយអនុសញ្ញាអន្តរជាតិដែលអាចអនុវត្តបានចំពោះមុខ អ.វ.ត.ក ទេ[2]។

២. នៅថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញា បានធ្វើការឆ្លើយតប ដោយលើកឡើងថា សំណើសុំនេះ ធ្វើឡើងដោយមិនត្រឹមត្រូវតាមវិធាន ៥៣(១)[3] ទេ និងថា មានលក្ខណៈខុសនីតិវិធី ដោយសារតែវាជាសំណើសុំដែលមិនមានចែងអនុញ្ញាតដោយវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាអះអាងថា JCE ត្រូវបានបង្កើតឡើង និងប្រើប្រាស់ចាប់តាំងពីសម័យតុលាការនៅក្រុង Nuremberg[4] មក ដូច្នេះវាមិនបានរំលោភលើគោលការណ៍ *nullum crimen sine lege* ទេ និងជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាពនៅចំពោះមុខ អ.វ.ត.ក[5]។

---

[1] D97 ទំព័រ ១ ទំព័រ ១៥។ D97/5 ផ្នែក I (ក) ។

[2] D97 ទំព័រ ១៥។ D97/7 ផ្នែក I (ខ-ច)។

[3] D97/II កថា. ៥។

[4] D97/II កថា. ២។

[5] D97/II កថា. ៣, ៤០។ D97/8 កថា. ៥១។

៣. នៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០០៨ មេធាវីការពារក្តី កាំង ហ្កេក អ៊ាវ បានបញ្ជាក់ថា ខ្លួនមិនមានសេចក្តីសំអាងដែលត្រូវធ្វើទៅលើបញ្ហានេះ[6]។ នៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៨ មេធាវីការពារក្តី អៀង ធីរិទ្ធ គាំទ្រចំពោះអំណះអំណាងដែលមាននៅក្នុងសំណើសុំ និងការកត់សំគាល់បន្ថែមរបស់ អៀង សារី[7]។ លើសពីនេះ មេធាវីការពារក្តី អៀង ធីរិទ្ធ អះអាងថា ជាជំនួសវិញ អ.វ.ត.ក មានយុត្តាធិការអនុវត្តត្រឹមតែ JCE ទម្រង់ទី ១ ("JCE ១") ប៉ុណ្ណោះ និងថា សហព្រះរាជអាជ្ញា បានលើកឡើងពី JCE ដោយមិនត្រឹមត្រូវនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[8]។ នៅថ្ងៃដដែល មេធាវីការពារក្តី នួន ជា បានដាក់សេចក្តីសន្និដ្ឋានគាំទ្ររបស់ខ្លួនចំពោះសេចក្តីសំអាងរបស់ អៀង សារី និងរបស់ អៀង ធីរិទ្ធ[9]។

៤. នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៩ មេធាវីការពារក្តី ខៀវ សំផន បានអះអាងថា ការបកប្រែឯកសារទៅជាភាសាបារាំងមិនគ្រប់គ្រាន់ ធ្វើឱ្យខ្លួនស្ថិតនៅក្នុងស្ថានភាពមិនស្មើភាពគ្នាបើប្រៀបធៀបនឹងភាគីទាំងអស់ដទៃទៀត និងបានស្នើឱ្យសហចៅក្រមស៊ើបអង្កេត ចាត់វិធានការចាំបាច់ដើម្បីស្តារឱ្យមានស្មើភាពគ្នាឡើងវិញ[10]។

៥. នៅថ្ងៃទី ៣០ ខែធ្នូឆ្នាំ ២០០៨ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួន ដោយបានគូសបញ្ជាក់ថា ការអនុវត្ត JCE ទី ៣ នៅចំពោះមុខ អ.វ.ត.ក គឺជាការរំលោភលើគោលការណ៍ *nullum crimen sine lege*[11]។

៦. នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៨ ការិយាល័យសហព្រះរាជអាជ្ញា បានធ្វើការកត់សំគាល់បន្ថែមរបស់ខ្លួន ដោយអះអាងថា សំណើសុំ និងការកត់សំគាល់របស់មេធាវីការពារក្តី គួរត្រូវបានបដិសេធចោល ដោយសារវាមានគោលបំណងប្រែក្លាយដំណើរការតុលាការជាបញ្ហានយោ

---

6 D97/3/1 កថា. ២ ។

7 D97/3/2 កថា. ១៣។

8 D97/3/2 កថា. ៣២។

9 D97/3/3 កថា. ២ ។

10 D97/3/5។

11 D97/3/4 កថា. ៣៤។

បាយ[12]។ សហព្រះរាជអាជ្ញា បានអះអាងសារជាថ្មីថា សហចៅក្រមស៊ើបអង្កេត គួរអនុវត្តទម្រង់នៃការទទួលខុសត្រូវ JCE ទាំងបី នៅចំពោះមុខ អ.វ.ត.ក[13]។

៧. នៅថ្ងៃទី ២៩ ខែមិថុនាឆ្នាំ ២០០៩ មេធាវីការពារក្តី អៀង សារី បានដាក់សំណើសុំឱ្យដាក់ទណ្ឌកម្មសហព្រះរាជអាជ្ញាអន្តរជាតិ ឬបុគ្គលិករបស់ ក.ស.ព[14] ដោយសារអាក់ខានមិនបានលាតត្រដាងពីសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ៩៨៨(V) ដែលទាក់ទិននឹងទំហំនៃការទទួលយកគោលការណ៍ Nuremberg[15]។ មេធាវីការពារក្តី នួន ជា[16] និងមេធាវីការពារក្តី ខៀវ សំផន[17] បានដាក់សេចក្តីសន្និដ្ឋានគាំទ្ររបស់ខ្លួនចំពោះសំណើសុំនេះ បន្ទាប់មកសហព្រះរាជអាជ្ញា បានដាក់ការឆ្លើយតបរបស់ខ្លួន[18] ហើយត្រូវបានឆ្លើយតបវិញពីមេធាវីការពារក្តី អៀង សារី[19]។ នៅថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០០៩ មេធាវីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបរបស់ខ្លួនដើម្បីគាំទ្រការបដិសេធសំណើសុំឱ្យដាក់ទណ្ឌកម្ម[20] ហើយត្រូវបានឆ្លើយតបវិញពីមេធាវីការពារក្តី អៀង សារី[21]។ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានចេញដីកាចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ បដិសេធសំណើសុំឱ្យដាក់ទណ្ឌកម្ម និងបានធ្វើការកត់សំគាល់លើសេចក្តីសន្និដ្ឋាន ទាក់ទិនឹងសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជា-ជាតិ ៩៨៨(V)[22]។

---

12 D97/8 កថា. ៥០។

13 D97/8 កថា. ៥១។

14 D97/9 ផ្នែក IV(ខ) ទំព័រ ៧-៨។

15 D97/9 ទំព័រ ៥-៦។ D97/12 ទំព័រ ៩។

16 D97/9/1 កថា. ១-៣។

17 D97/9/3។

18 D97/9/2 កថា. ២-៧។

19 D97/9/4 កថា. ២។ D97/12។

20 D97/9/5 កថា.១៧។

21 D97/9/6 កថា.២៣។

22 D97/7 កថា.១៣។

## ២) សំអាងហេតុនៃសេចក្ដីសម្រេច

### *ក) បញ្ហានីតិវិធី*

៨. មេធាវីការពារក្ដី អៀង សារី បានស្នើសុំ សហចៅក្រមស៊ើបអង្កេត ឱ្យចេញដីកាមួយថា តើខ្លួននឹងអនុវត្ត ឬក៏មិនអនុវត្តទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថា JCE ។ យោងតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ភាគី អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត "ចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា*ចាំបាច់* ដល់ការស៊ើបសួរ"[23]។ វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ផ្ដល់ឆន្ទានុសិទ្ធិទៅឱ្យភាគីពាក់ព័ន្ធនានា រួមទាំងជនត្រូវចោទផង ក្នុងការកំណត់ថា តើដីកា ឬកិច្ចស៊ើបសួរណាដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើដូច្នេះមែន ដូចដែលបានលើកឡើងដោយ ក.ស.ព សំណើសុំរបស់ អៀង សារី ត្រូវបានធ្វើឡើងដោយមានការភាន់ច្រឡំ ពីព្រោះផ្អែកតាមវិធាន ៥៣(១) នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ក.ស.ព សហចៅក្រមស៊ើបអង្កេត សម្រេចដោយតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនផ្ទាល់ ធ្វើការពិចារណាសំណើសុំនេះ ដោយយោងទៅលើវិធានផ្ទៃក្នុងដែលត្រឹមត្រូវ គឺវិធាន ៥៥(១០)។

៩. ក.ស.ព ក៏បានជំទាស់ផងដែរនឹងទម្រង់នៃការឆ្លើយតបដែលមេធាវីការពារក្ដី អៀង សារី ចង់បាន។ សហចៅក្រមស៊ើបអង្កេត ធ្វើការកត់សំគាល់ថា ទម្រង់នៃការឆ្លើយតបរបស់ខ្លួនទៅនឹងសំណើសុំរបស់ភាគីណាមួយ នឹងមានការប្រែប្រួល ទៅតាមប្រភេទនៃសំណើសុំនោះ។ អាស្រ័យដោយភាគីនានា មានឆន្ទានុសិទ្ធិ នៅក្នុងធ្វើសំណើសុំ សហចៅក្រមស៊ើបអង្កេត ក៏ត្រូវមាន

---

[23] សហចៅក្រមស៊ើបអង្កេត កត់សំគាល់ឃើញថា
មានការខុសគ្នាបន្តិចត្រង់ពាក្យពេចន៍នៃវិធាន៥៥(១០)ក្នុងជាភាសាខ្មែរ និងភាសាបារាំង បើធៀបទៅនឹងភាសាអង់គ្លេស៖ *នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា<u>មានប្រយោជន៍</u> ដល់ការស៊ើបសួរ* ។ <u>(គូសបន្ទាត់បន្ថែម)</u>

ឆន្ទានុសិទ្ធិ ដូចគ្នាក្នុងការកំណត់ពីទម្រង់នៃការឆ្លើយតបដែរ[24]។

**១០.** បញ្ហាដែលបង្កើតជាមូលដ្ឋានសម្រាប់ការស្នើសុំនាពេលនេះ គឺលើកឡើងពីបញ្ហានៃការជូនដំណឹងឱ្យបានត្រឹមត្រូវដល់ជនត្រូវចោទ លើទម្រង់នៃការទទួលខុសត្រូវដែលអាចយកមកប្រើ។ ការជូនដំណឹងដ៏ត្រឹមត្រូវអាចធ្វើឡើងនៅក្នុងអំឡុងពេលនៃការស៊ើបសួរ ឬនៅពេលចេញដីកាដំណោះស្រាយទៅតាមករណីសមស្រប។ ពាក្យ "សហឧក្រិដ្ឋកម្មរួមមិនមានចែងច្បាស់ទេនៅក្នុងច្បាប់ និងក្នុងកិច្ចព្រមព្រៀង។ ជាគោលការណ៍ សហចៅក្រមស៊ើបអង្កេតតែងតែបដិសេធមិនចេញសេចក្ដីសម្រេចដែលជាការបកស្រាយច្បាប់សុទ្ធសាធ ប៉ុន្តែនៅក្នុងករណីនេះ សហចៅក្រមចាំបាច់ត្រូវតែឆ្លើយតបទៅនឹងសំណើនេះដើម្បីផ្ដល់នូវព័ត៌មានគ្រប់គ្រាន់ស្ដីអំពីទំរង់នៃការទទួលខុសត្រូវ ដែលមិនមានចែងច្បាស់នៅក្នុងច្បាប់ អ.វ.ត.ក. និងកិច្ចព្រមព្រៀង។ នៅក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា សំណើសុំមានលក្ខណៈច្បាស់លាស់ និងសមហេតុផល[25]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតបដិសេធចំពោះសំណើរបស់ ក.ស.ព ដែលសុំឱ្យសម្រេចថា សំណើរបស់មេធាវីការពារក្ដី គឺជាសំណើដែលមិនអាចទទួលយកបានដោយសារតែប្រភេទនៃសំណើនេះ។

**១១.** សហចៅក្រមស៊ើបអង្កេត បានទទួលលិខិតពីមេធាវីការពារក្ដី ខៀវ សំផន ស្នើសុំឱ្យមានការបកប្រែទៅជាភាសាបារាំងនូវឯកសារមួយចំនួននៅក្នុងសំណុំរឿងដែលពាក់ព័ន្ធនឹងសំណើសុំនេះ[26]។ សហចៅក្រមស៊ើបអង្កេត សូមរំលឹកឡើងវិញពីដីកាកន្លងមកទាក់ទិននឹងការបកប្រែ[27]

---

[24] សំណុំរឿង លេខ ០០២/១៩-០៩-២០០៩-អវតក/កសចស (អបជ២៤) *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្ដុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម* , អវតក អង្គបុរេជំនុំជម្រះ ១៨ វិច្ឆិកា ២០០៩ (D164/4/13) កថាខ័ណ្ឌ ២២។

[25] D164/4/13 កថាខ័ណ្ឌ ៤៤-៤៦។

[26] D97/3/5។

[27] សំណុំរឿង លេខ ០០២/១៩-០៩-២០០៩-អវតក/កសចស *ដីកាសម្រេចស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទិននឹងការបកប្រែ* អវតក/កសចស ១៩ មិថុនា ២០០៨ (A190) ទំព័រ ២-៤។ សំណុំរឿង លេខ ០០២/១៩-០៩-២០០៩-អវតក/កសចស *ដីកាសម្រេចលើ "បណ្ដឹងសុំមោឃភាពដោយមូលហេតុរំលោភនីតិវិធី"*, អ.វ.ត.ក/កសចស ២៩ កញ្ញា ២០០៩ (D197/4) ទំព័រ ២-៤។

និងសាលដីកាដែលពាក់ព័ន្ធរបស់អង្គបុរេជំនុំជម្រះ[28]។ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា សេចក្តីសម្រេចទាំងនេះ ឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើងដោយមេធាវីការពារក្តី និង ថាមិនចាំបាច់ធ្វើការបញ្ជាក់បន្ថែមលើបញ្ហានេះទៀតទេ។

*ខ) ធាតុផ្សំនៃសហឧក្រិដ្ឋកម្មរួម*

**១២.** សំណើសុំពាក់ព័ន្ធនឹងការអនុវត្តទម្រង់ពិសេសមួយនៃការទទួលខុសត្រូវ ដែលមានឈ្មោះថា JCE។ បទប្បញ្ញត្តិនៅក្នុងច្បាប់ អ.វ.ត.ក ដែលពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវជាបុគ្គល គឺមាត្រា ២៩ ដែលចែងថា៖

> ជនសង្ស័យណាមួយដែលមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយ និងជម្រុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣ ថ្មី មាត្រា ៤ មាត្រា ៥ មាត្រា ៦ មាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ។

**១៣.** មាត្រា ២៩ មិនមានចែងច្បាស់លាស់អំពី JCE នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ JCE គឺជាទំរង់នៃការទទួលខុសត្រូវមួយ ដែលត្រូវបានទទួលស្គាល់ថាជាទំរង់នៃការប្រព្រឹត្តនៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍រឿងក្តី Tadic នៅ ICTY។ JCE មានបីទំរង់ខុសៗគ្នា ប៉ុន្តែលក្ខណៈរួមរបស់ JCE ទាំងបីប្រភេទនេះគឺ ធាតុផ្សំសត្យានុម័ត *(actus reus)*។ ដូច្នេះ លក្ខណៈវិនិច្ឆ័យដើម្បីធ្វើការបែងចែក JCE ទាំងបីទំរង់នេះ គឺកំរិតខុសគ្នានៃធាតុផ្សំអត្តនោម័ត *(mens rea)*។

**១៤.** ធាតុផ្សំសត្យានុម័ត ដែលជាលក្ខណៈរួមនៃ JCE ទាំងបីប្រភេទ រួមមាន៖

---

[28] សំណុំរឿង លេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១២) *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទិននឹងការបកប្រែ* អ.វ.ត.ក អង្គបុរេជំនុំជម្រះ ២០ កុម្ភៈ ២០០៨ (A190/II/9)។ សំណុំរឿង លេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១១) *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទិននឹងការបកប្រែ,* អ.វ.ត.ក អង្គបុរេជំនុំជម្រះ ២០ កុម្ភៈ ២០០៨ (A190/I/20)។

i) មានអ្នកចូលរួមប្រព្រឹត្តច្រើន[29]

ii) អត្ថិភាពនៃគោលបំណងរួម (ឬ ផែនការរួម) ដែលពាក់ព័ន្ធជាមួយនឹងការប្រព្រឹត្ត បទឧក្រិដ្ឋកម្ម ដែលមានចែងក្នុងច្បាប់[30]។

iii) ជនត្រូវចោទត្រូវតែបានចូលរួមក្នុងផែនការរួមនោះ[31]។

**១៥.** ចំពោះធាតុផ្សំអត្តនោម័តវិញ នៅក្នុងទំរង់ទីមួយ (ទំរង់ជាមូលដ្ឋាន) នៃ JCE ("JCE I") ជនត្រូវចោទត្រូវតែមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋកម្ម ហើយចេតនានេះត្រូវតែជាចេតនារួមរបស់អ្នកចូលរួមប្រព្រឹត្តទាំងអស់[32]។ ចំណែកឯទំរង់ទីពីរ (លក្ខណៈជាប្រព័ន្ធ) នៃ JCE វិញ ("JCE II") គឺទាញចេញពីប្រភេទ JCE I និងដែលទាក់ទងជាមួយនឹងប្រព័ន្ធសហការរួមនៃការប្រព្រឹត្តអំពើឃោរឃៅ ដែលជនត្រូវចោទបានដឹងអំពីសារជាតិនៃប្រព័ន្ធនេះ និងមានឆន្ទៈគាំទ្រដល់ប្រព័ន្ធសហការរួមនេះ[33]។

**១៦.** ទំរង់ទីបី (ទំរង់លាតសន្ធឹង) នៃ JCE ("JCE III") ពាក់ព័ន្ធជាមួយនឹងអំពើ ដែលជាផលវិបាកជាលក្ខណៈធម្មជាតិ និងអាចព្យាករជាមុននៃផែនការរួម ទោះបីជាអំពីនោះមិនថិតនៅក្នុងផែនការរួម ដែលជនត្រូវចោទមានចេតនាចូលរួមក៏ដោយ។ ជនត្រូវចោទត្រូវដឹងថា បទល្មើសដែលមិនថិតនៅក្នុងផែនការរួម គឺជាផលវិបាកជាធម្មជាតិ និងអាចមើលឃើញជាមុននៃផែនការរួមនោះ និងបានទទួលយកដោយចេតនានូវហានិភ័យនេះ[34]។

---

29 សូមមើល IT-98-30/1-A Kvocka et al សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ កថា. ៨១

30 សូមមើល IT-00-39A Krajisnik សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ កថា. 57-102, 206-251, 163។ IT-97-25-A Krnojelac សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ កថា. 31។ សូមមើលផងដែរ IT-99-36T Brdjanin សេចក្តីសម្រេចសាលាដំបូង កថា. 342។

31 សូមមើល IT-98-30/1-A Kvocka et al សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ កថា. ៨១, ១១២-១១៣ និង ៤២១

32 IT-94-1-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ រឿងក្តី Tadic កថា. 196

33 IT-94-1-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ រឿងក្តី Tadic កថា. 203

34 សូមមើល IT-94-1-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ រឿងក្តី Tadic កថា. 203, 204។ ដែលផ្ទុយពី IT-98-30/1-A Kvocka និង ជនផ្សេងទៀត សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ថ្ងៃ ២៨ កុម្ភៈ ២០០៥ កថា. ៨៦ "អ្នកចូលរួមប្រព្រឹត្តបទល្មើសអាចត្រូវទទួលខុសត្រូវចំពោះបទល្មើសក្នុងករណីដែលអយ្យការបង្ហាញថាជនត្រូវចោទបានដឹងច្បាស់ លាស់ថា បទល្មើសនោះជាផលវិបាកជាធម្មជាតិ និងអាចមើលឃើញជាមុន"។

១៧. ដោយសារថា JCE II ទាញចេញពីប្រភេទ JCE I ធាតុផ្សំអត្តនោម័តពីរ ដែលនឹងត្រូវពិនិត្យ និងវាយតម្លៃដោយសហចៅក្រមស៊ើបអង្កេតគឺ "ចេតនា" ដែលមានក្នុង JCE I និង "ផលវិបាកជាលក្ខណៈធម្មជាតិ និងអាចព្យាករជាមុន" ដែលមានក្នុង JCE III។

*គ) គោលការណ៍នីត្យានុកូលភាព*

១៨. ដើម្បីអាចឱ្យទ្រឹស្តីព្រហ្មទណ្ឌមួយ ដូចជា JCE ត្រូវបានគេប្រើប្រាស់បាននៅក្នុងដំណើរការនីតិវិធីតុលាការ គោលការណ៍នីត្យានុកូលភាព (គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង) ទាមទារឱ្យមានការវាយតម្លៃថាតើទ្រឹស្តីព្រហ្មទណ្ឌនោះ គឺជាច្បាប់ដែលអាចអនុវត្តបាននៅពេលដែលអង្គហេតុដែលជាកម្មវត្ថុនៃកិច្ចស៊ើបសួរកើតឡើង ដែរ ឬទេ។

១៩. មាត្រា ៣៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មានចែងអំពីគោលការណ៍នីត្យានុកូលភាព ដោយធ្វើការយោងទៅដល់មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦[35]។ មាត្រា ១៥ នៃកតិកាសញ្ញានេះ ត្រូវបានយកមកប្រើផងដែរដោយ ICTY ដើម្បីបញ្ជាក់អំពីខ្លឹមសារនៃគោលការណ៍នីត្យានុកូលភាព។ សេចក្តីសម្រេចនៃសភាឧទ្ធរណ៍របស់ ICTY បានយោងទៅដល់គំនិតពិចារណាសំខាន់មួយចំនួន ដើម្បីវាយតម្លៃអំពីគោលការណ៍នីត្យានុកូលភាព ជាពិសេស ចំពោះចំណុចដែលថា៖

> ការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងករណីនេះ គឺពិតជាអាចព្យាករជាមុន និងថាច្បាប់ដែលចែងអំពីការទទួលខុសត្រូវនេះ ត្រូវតែអាចរកបាន ក្នុងពេលវេលាដែលពាក់ព័ន្ធនោះ ដើម្បីជាសំអាងនៃការចោទប្រកាន់ និងកាត់ទោសនៅក្រោមទំរង់នៃការទទួលខុសត្រូវ ដែលសម្រេចដោយអយ្យការ[36]។

---

[35] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ មាត្រា ១៥ ចូលជាធរមានថ្ងៃ ២៣ មីនា ១៩៧៦។

[36] IT-05-98 Milutinovic et al. សេចក្តីសម្រេចលើសំណើសុំបដិសេធយុត្តាធិការរបស់ Dragoljob JCE ថ្ងៃ ២១ ឧសភា ២០០៣ កថា. 37

២០. ការវាយតម្លៃអំពីភាពដែលអាចមើលឃើញជាមុន និងភាពដែលអាចរកបាន អាចធ្វើទៅបាន នៅពេលដែលអំពើដែលចោទប្រកាន់នោះ ត្រូវបានផ្តន្ទាទោសនៅក្រោមបញ្ញត្តិច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៃពេលវេលាជាក់លាក់ណាមួយ។ សេចក្តីសម្រេចតុលាការ និងលិខិតតូបករណ៍ច្បាប់អន្តរជាតិ គឺជាផ្លូវណែនាំក្នុងការវាយតម្លៃអំពីភាពដែលអាចមើលឃើញជាមុន និងភាពដែលអាចរកបាន នៃបទដ្ឋានច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងចរិតលក្ខណៈ និងភាពធ្ងន់ធ្ងរនៃអង្គហេតុដែលចោទប្រកាន់[37]។

២១. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយ អ.វ.ត.ក. គឺជាការសន្និដ្ឋានដែលទាញចេញអំពីហេតុដែលថា អ.វ.ត.ក. មានចរិតលក្ខណៈជាតុលាការអន្តរជាតិ ដែលអនុវត្តច្បាប់អន្តរជាតិ[38]។ ដោយយោងទៅលើចរិតលក្ខណៈអន្តរជាតិរបស់ អ.វ.ត.ក. នេះ និងដោយបានពិចារណាឃើញថា យុត្តិសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃអំពី JCE ត្រូវបានតាក់តែងឡើងមុនពេលនៃអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរនៅមុខ អ.វ.ត.ក. កើតមានឡើង[39] សហចៅក្រមស៊ើបអង្កេតយល់ឃើញថា JCE អាចអនុវត្តបានដោយផ្អែកលើមូលដ្ឋានដែលមានកំណត់នៅក្នុងច្បាប់អន្តរជាតិ ដូចដែលមានលើកឡើងនៅក្នុងកថាខណ្ឌ ១៤-១៧ រួមទាំង កំណត់យោងចុងទំព័រដែលទាក់ទងនឹងការវាយតម្លៃជាអត្តនោម័តនៃផលវិបាកជាលក្ខណៈធម្មជាតិ និងអាចព្យាករជាមុន[40]។

---

[37] ដូចយោងខាងលើ កថា. 37 និងបន្តបន្ទាប់

[38] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (PTC01) ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កាំង ហ្កេកអ៊ាវ ហៅ ឌុច អង្គបុរេជំនុំជម្រះ អ.វ.ត.ក. ថ្ងៃ ០៣ ធ្នូ ២០០៧ (C5/45) កថា. ២០

[39] IT-94-1-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ រឿងក្តី Tadic កថា. 185 និងបន្តបន្ទាប់

[40] Kvocka និង ជនផ្សេងទៀត សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ថ្ងៃ ២៨ កុម្ភៈ ២០០៥ កថា. ៨៦ “អ្នកចូលរួមប្រព្រឹត្តបទល្មើសអាចត្រូវទទួលខុសត្រូវចំពោះបទល្មើសក្នុងករណីដែលអយ្យការបង្ហាញថាជនត្រូវចោទបានដឹងច្បាស់លាស់ថា បទល្មើសនោះជាផលវិបាកជាធម្មជាតិ និងអាចមើលឃើញជាមុន”

## ឃ) ការអនុវត្ត JCE ចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិ

**២២.** ឧក្រិដ្ឋកម្មអន្តរជាតិ ដែលមានចែងដោយមាត្រា ៤ ដល់មាត្រា ៨ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ពាក់ព័ន្ធជាពិសេសជាមួយនឹងបុគ្គល ដែលមានការទទួលខុសត្រូវខ្ពស់បំផុត ដែលការទទួលខុសត្រូវនេះក៏អាចរាប់បញ្ចូលផងដែរនូវអំពើ ដែលមិនបានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់[41]។ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិបានឆ្លើយតបចំពោះបញ្ហានេះតាមរយៈទំរង់នៃការទទួលខុសត្រូវ ដូចជាការទទួលខុសត្រូវរបស់មេកើយ ឬ JCE[42]។ ទោះបីជាយ៉ាងណាក្តី យើងមិនអាចអះអាងបានទេថា ទំរង់នៃការទទួលខុសត្រូវបែបនេះអាចអនុវត្តហួសពីក្របខណ្ឌនៃឧក្រិដ្ឋកម្មអន្តរជាតិនេះទេ។ សហចៅក្រមស៊ើបអង្កេតសូមរំលឹកថា ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ យកគំរូតាមច្បាប់បារាំង[43] ហើយនៅក្នុងច្បាប់បារាំងនេះ ឧក្រិដ្ឋកម្មអន្តរជាតិ តួយ៉ាងឧក្រិដ្ឋកម្មអន្តរជាតិដែលឋិតក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក. គឺជាឧក្រិដ្ឋកម្មដែលមានលក្ខណៈពិសេសឋិតក្នុង "របបគតិយុត្ត" ពិសេសដាច់ដោយឡែកមួយ ផ្សេងពីច្បាប់ព្រហ្មទណ្ឌ

---

[41] តុលាការអន្តរជាតិ និងកូនកាត់ជាច្រើន រួមទាំង អ.វ.ត.ក. ផង កំណត់យុត្តាធិការរបស់ខ្លួនត្រឹមមេដឹកនាំជាន់ខ្ពស់ ឬអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត។ សូមមើល៖ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងខ្លឹមសារវិសោធនកម្មថ្ងៃ ២៧ តុលា ២០០៤ មាត្រា ១ (ថ្មី) "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ លក្ខន្តិកៈតុលាកាសម្រាប់ស៊ីរ៉ាលេអូន មាត្រា ១(១) "ជនដែលមានការទទួលខុសត្រូវខ្ពស់បំផុត"។ លក្ខន្តិកៈក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ "បទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត" សូមមើលផងដែរ *Attorney General of Israel v. Adolf Eichmann*, District Court of Jerusalem, Judgement of 12 December 1961, 36 ILR 18 (1968), para. 197, as cited in Schomburg's Separate Opinion in IT-95-11-A, *Martić* Appeal Judgement, para. 8, and in Shahabudeen Separate's Opinion in IT-98-29-A, *Galić* Appeal Judgement, para. 44.

[42] IT-94-1-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ រឿងក្តី Tadic កថា. 190-193

[43] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សេចក្តីផ្តើមនីតិកម្ពុជា រោងពុម្ព ហ្វូណាន (២០០៥) ទំ. ១២ កថា. ២៩។ ស្ថាប័នធម្មនុញ្ញ និងនយោបាយនៃកម្ពុជា របស់លោក Claude-Gilles Gour រោងពុម្ព Dalloz (1965) ទំ. ៣៨៩។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (PTC) ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំង នឹងដីកាដំណោះស្រាយករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច អង្គបុរេជំនុំជម្រះ អ.វ.ត.ក. ថ្ងៃ ០៥ ធ្នូ ២០០៨ note 37 (C99/3/42)។

ជាតិ និងត្រូវបានសម្គាល់ដោយចរិតលក្ខណៈពិសេសនៃវិធាននីតិវិធី និងច្បាប់[44]។ សហចៅក្រមស៊ើបអង្កេតសូមរំលឹកថា អ.វ.ត.ក. ក៏ជាស្ថាប័នដែលមានលក្ខណៈជាតុលាការអន្តរជាតិដែរ[45] ហើយច្បាប់ និងកិច្ចព្រមព្រៀង អ.វ.ត.ក. បានផ្តល់សមត្ថកិច្ចយុត្តាធិការឱ្យ អ.វ.ត.ក. ទាំងលើឧក្រិដ្ឋកម្មជាតិ និងឧក្រិដ្ឋកម្មអន្តរជាតិ។ ទោះបីជាយ៉ាងនេះក្តី អនុលោមតាមគោលការណ៍នៃការបកស្រាយលើរបបគតិយុត្តពិសេស ស្របទៅតាមច្បាប់ប្រទេសបារាំង ទំរង់នៃការទទួលខុសត្រូវនៃឧក្រិដ្ឋកម្មអន្តរជាតិអាចត្រូវបានអនុវត្តចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិតែប៉ុណ្ណោះ។ ចំណុចនេះវាពិតជាត្រឹមត្រូវណាស់ ខណៈដែល JCE មិនត្រូវបានចែងច្បាស់លាស់នៅក្នុងច្បាប់ ឬកិច្ចព្រមព្រៀងនោះទេ ហើយកន្លងមកវាធ្លាប់តែត្រូវបានប្រើប្រាស់នៅក្នុងរឿងក្តីអន្តរជាតិ ទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិតែប៉ុណ្ណោះ។ ធាតុផ្សំនៃ JCE ដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញថា អាចត្រូវអនុវត្តបាននៅ អ.វ.ត.ក. អាចអនុវត្តចំពោះតែឧក្រិដ្ឋកម្មអន្តរជាតិតែប៉ុណ្ណោះ និងមិនអាចអនុវត្តចំពោះបទល្មើសក្នុងច្បាប់ជាតិនោះទេ។

**២៣.** ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ធាតុផ្សំនៃ JCE ដែលមានលើកឡើងនៅក្នុងផ្នែកសេចក្តីសម្រេចខាងក្រោម អាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ក្រោមយុត្តាធិការនៃ អ.វ.ត.ក.។ អនុលោមតាមការវិភាគខាងលើ ធាតុផ្សំនៃទំរង់នៃការទទួលខុសត្រូវ ដែលជាកម្មវត្ថុនៃសំណើសុំនេះ មានលក្ខណៈអាចព្យាករជាមុន និងអាចរកបាននៅក្រោមបញ្ញត្តិនៃច្បាប់អន្តរជាតិ នៅក្នុងឆ្នាំ ១៩៧៥ នៅក្នុងប្រទេសកម្ពុជា ដោយស្របទៅតាមគោលការណ៍នីត្យានុកូលភាព។ ទិដ្ឋភាពទាំងនេះត្រូវបានលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាពិសេសនៅក្នុងផ្នែកដែលពាក់ព័ន្ធជាមួយនឹងផែនការឧក្រិដ្ឋកម្មរួម (កថា. ៥-១៦) នៅក្នុងកថាខណ្ឌដែលពាក់ព័ន្ធនឹងការចូលរួម និងការដឹងឮរបស់ជនត្រូវចោទ និងកថាខណ្ឌ ១១៦។

---

[44] នីតិព្រហ្មទណ្ឌទូទៅ Economica ការបោះផ្សាយលើកទី ៩ ២០០២ ទំ. ១៧៧ កថា. ១៧៤ របស់លោក Desportes F. Le Gunehec F.។

[45] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (PTC01) ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កាំង ហ្គេកអ៊ាវ ហៅ ឌុច អង្គបុរេជំនុំជម្រះ អ.វ.ត.ក. ថ្ងៃ ០៣ ធ្នូ ២០០៧ (C5/45) កថា. ២០

00411046

លេខ/ No: D97/13

## អាស្រ័យហេតុនេះ

**សម្រេចថា** ទំរង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម (JCE) នេះ មិនអាចអនុវត្តបានចំពោះបទល្មើសជាតិឡើយ។

**នាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិ**

- **សម្រេច** បដិសេធសំណើសុំដែលធ្វើមកនេះ ដោយហេតុថា *ធាតុផ្សំសត្យានុម័ត* និង *ធាតុផ្សំអត្តនោម័ត* នៃ JCE I អាចអនុវត្តនៅ អ.វ.ត.ក.។
- **សម្រេច** បដិសេធសំណើសុំដែលធ្វើមកនេះ ដោយហេតុថា *ធាតុផ្សំសត្យានុម័ត* និង *ធាតុផ្សំអត្តនោម័ត* នៃ JCE II អាចអនុវត្តនៅ អ.វ.ត.ក.។
- **សម្រេច** បដិសេធសំណើសុំដែលធ្វើមកនេះ ដោយហេតុថា *ធាតុផ្សំសត្យានុម័ត* នៃ JCE III អាចអនុវត្តនៅ អ.វ.ត.ក.។
- **សម្រេច** ទទួលយកដោយផ្នែកនូវសំណើសុំដែលធ្វើមកនេះ ដោយហេតុថាធាតុផ្សំអត្តនោម័តនៃ JCEIII ដែលអាចត្រូវអនុវត្តបាននៅមុខ អ.វ.ត.ក. គឺមានតែការទទួលយកជាអត្តនោម័តនៃផលវិបាកជាលក្ខណៈធម្មជាតិ និងអាចព្យាករបាននៃការអនុវត្តផែនការរួមតែប៉ុណ្ណោះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

យូ ប៊ុនឡេង

**Marcel LEMONDE**